**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

សំរាប់ កម្ពុជា
សង្គម ការពារ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ៥៧៤ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦៣ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦៣ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្ដីជូនដំណឹងចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
### ចំនួន ៦៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 33 |
| 1 | ក្រុមហ៊ុន មិន រ៉ុង ហ្គាម៉ិន ហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អេធិច អ៊ិនធើណេសិនណល(ខេមបូឌា)អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ថុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហេជ ហ្គា(ខេមបូឌា)ហ្គាម៉ិន ហ្វេកធើរី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន វ៉ាយ អេស ស៊ី យ៉ក់សាន់ស្ពារ(ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន វ៉ូជុង អ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ខូហឺស្ត (ខេមបូឌា) ខូអ៊ិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អេធិច អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន អ៊ីអឹមប៊ី ផែលកូរី (ខេមបូឌា) | ភ្នំពេញ |
| 10 | ក្រុមហ៊ុន វ៉ាយ វី គី ត្រេឌីង | ភ្នំពេញ |
| 11 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្ដាល |
| 12 | ក្រុមហ៊ុន គ្លោរីង វែលយូ (ខេមបូឌា) ប៉េក &ឡាក់ហ្គេជ ឯ.ក | កណ្ដាល |
| 13 | ក្រុមហ៊ុន រ៉ូយ៉ាល់ អ៊ិនណូថេក នីតវែរ ឯ.ក | កណ្ដាល |
| 14 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្ដាល |
| 15 | ក្រុមហ៊ុន យឺង ហ្វ៊ីស អ៊ិនដាសស្ទ្រៀល | កណ្ដាល |
| 16 | ក្រុមហ៊ុន ឃ្វៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្ដាល |
| 17 | ក្រុមហ៊ុន បូវឃើ ហ្គាមេន ព្រីនធីង(ខេមបូឌា)ខមភេនី លីមីធីត | កណ្ដាល |
| 18 | ក្រុមហ៊ុន វ៉ាយ អិម ជី ហ្គាមេន អេកសេសើរី | កណ្ដាល |
| 19 | ក្រុមហ៊ុន វីកូតិច អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុន ស៊ីគ្គ (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុន លីវ តាន អ៊ិនធើណេសិនណល ខេមបូឌា ខូអិលធីឌី | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន អេស យ៉ន (ខេមបូឌា) អឹមភែរីល ខូល ធី ឌី | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុន ជាតធេច (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុន ហឺវ៉ាយហ្សិន អៅដរ(ខេមបូឌា)ខូ,.អិលធីឌី | កំពង់ឆ្នាំង |
| 25 | ក្រុមហ៊ុន ហាផ់រអ៊ិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 26 | ក្រុមហ៊ុន ហ៊ែលសា សៅ អ៊ិស អេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| 27 | ក្រុមហ៊ុន យឹង អ៊ីធើណល (ខេមបូឌា) | ស្វាយរៀង |
| 28 | ក្រុមហ៊ុន សោន 868 ឯ.ក | ស្វាយរៀង |
| 29 | ក្រុមហ៊ុន ខេមបូឌាន យុនគុន ឯ.ក | ព្រះសីហនុ |
| 30 | ក្រុមហ៊ុន លីឌើ អ៊ិនដាស្ទ្រៀល ខូអេលធីឌី | ព្រះសីហនុ |
| 31 | ក្រុមហ៊ុន ញូវ ស្តារ ស៊ូ ខូអិលធីឌី | ព្រះសីហនុ |
| 32 | ក្រុមហ៊ុន ខេមបូឌាន សាន់វ៉ាយ៍ ហ្គាមេន ខូអិលធីឌី | ព្រះសីហនុ |
| 33 | ក្រុមហ៊ុន អិលខេ ឡាក់ហ្គេដ | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 30 |
| 34 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 35 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 36 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 37 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 38 | សណ្ឋាគារ រ៉ាហ្វែល រ៉ូយ៉ាល់ | ភ្នំពេញ |
| 39 | ក្រុមហ៊ុន អេស៊ា អិចផ្លរើ ត្រាវែល | ភ្នំពេញ |
| 40 | ក្រុមហ៊ុន អលទ្រីម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 41 | ក្រុមហ៊ុន វីត្រូ អ៊ិនវេសមេន | សៀមរាប |
| 42 | ក្រុមហ៊ុន រេសចីរេន ខូឡិចហ្សិន | សៀមរាប |
| 43 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវែល ស៊ែរវីស | សៀមរាប |
| 44 | ក្រុមហ៊ុន កាឡាស ខម(ខេមបូឌា)ភីធីអ៊ី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉) | សៀមរាប |
| 45 | ផ្ទះសំណាក់ សាគូអង្គ | សៀមរាប |
| 46 | សណ្ឋាគារ គោព្រៃ | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 47 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស | សៀមរាប |
| 48 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ជាឡេស) | សៀមរាប |
| 49 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 50 | ក្រុមហ៊ុន កូបេ យៃកែននីស រែស្វូរែន | សៀមរាប |
| 51 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 52 | ក្រុមហ៊ុន អេវីតាស II | សៀមរាប |
| 53 | ក្រុមហ៊ុន ដំណាក់ឃៃភីថល ឯ.ក | សៀមរាប |
| 54 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( អង្គរធីខេត្រាវែល ធូរ) | សៀមរាប |
| 55 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 56 | សណ្ឋាគារ ស្ទឹងសៀមរាបថ្មី | សៀមរាប |
| 57 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេចតុមុខ) | សៀមរាប |
| 58 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេមេគង្គ) | សៀមរាប |
| 59 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 60 | ក្រុមហ៊ុន ហ្វូខឹស អេស៊ា អ៊ីនធើណេសិនណលត្រាវែល សឺវីស | សៀមរាប |
| 61 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 62 | សណ្ឋាគារ សោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 63 | ក្រុមហ៊ុន ហាប់ ហេង អ៊ិនវេសមេន ភីធីអ៊ី អិលធីឌី | សៀមរាប |